ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Preliminaire

D350/1/1/4

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ៤៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០១៧

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 09 / 2017
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**សាធារណៈ: កោសលុប**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ [redacted]**
**សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី [redacted]**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានទទួល “បណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល” ដែលត្រូវបានដាក់ដោយសហមេធាវីរបស់ [redacted] ( “សហមេធាវី” និង “ដើមបណ្តឹងឧទ្ធរណ៍”) នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧ (“បណ្តឹងឧទ្ធរណ៍”)[1]។

## I. **សេចក្តីផ្តើម**

1. បណ្តឹងឧទ្ធរណ៍នេះទាក់ទងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ”) ដែលបានបដិសេធពាក្យសុំរបស់ដើមបណ្តឹងឧទ្ធរណ៍សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល (“ដីកាសម្រេចដែលរងការជំទាស់”)[2]។

## II. **ប្រវត្តិនីតិវិធី**

2. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីបានដាក់ជូនការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) នូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ដោយបានចោទប្រកាន់អំពីការជាប់ពាក់ព័ន្ធរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងអំពើឧក្រិដ្ឋ និង ស្នើ ចោទប្រកាន់មកលើរូបគាត់ (“ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ”)[3]។

---

[1] បណ្តឹងឧទ្ធរណ៍របស់ [redacted] ចំពោះដីកាសម្រេចលើពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧, ឯកសារ D350/1/1/2 ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧។

[2] ដីកាសម្រេចស្តីពីពាក្យសុំរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧, ឯកសារ D350/1, ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៧។

[3] សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (“សំណុំរឿង ០០៤”) ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨, ឯកសារ D1។ សំណុំរឿង ០០៤, សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបី, ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩, ឯកសារ D1/1។

3. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៦ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានចេញសេចក្តីជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំងដើមបណ្តឹងឧទ្ធរណ៍[4] ដែលអមដោយសេចក្តីជូនដំណឹងទីពីរអំពីការបិទបញ្ចប់នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧[5]។

4. នៅថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីបានដាក់ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូលអនុលោមតាមវិធាន៧៦(២)នៃវិធានផ្ទៃក្នុង ("ពាក្យសុំ")[6]។ នៅថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៧ ស.ច.ស.អ បានចេញដីកាសម្រេចដែលរងការជំទាស់[7]។ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចដែលរងការជំទាស់[8]។ នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ សហមេធាវីបានដាក់សំណើសុំដាក់ជាភាសាអង់គ្លេសជាមុនសិន ដោយឯកសារបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[9]។ បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៧[10]។ សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") បានដាក់ចម្លើយតបរបស់គាត់នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១៧[11]។ សហមេធាវីមិនបានដាក់ការឆ្លើយតបទៅនឹងចម្លើយតបនេះទេ។

---

[4] សេចក្តីជូនដំណឹងអំពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំង [redacted], ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦, ឯកសារ D334។

[5] សេចក្តីជូនដំណឹងលើកទីពីរអំពីការបិទបញ្ចប់កិច្ចស៊ើបសួរប្រឆាំង [redacted], ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៧, ឯកសារ D334/2។

[6] ពាក្យសុំឱ្យអង្គបុរេជំនុំជម្រះពិចារណាធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧, ឯកសារ D350។

[7] *សូមមើល ខាងលើ*ជើងទំព័រ ២។

[8] ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើសំណើរបស់ [redacted] សុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៧, ឯកសារ D350/1/1, ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៧។

[9] សំណើសុំការអនុញ្ញាតដើម្បីដាក់ជាភាសាអង់គ្លេសជាមុននូវបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំរបស់ [redacted] ធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧, ឯកសារ D350/1/1/1។

[10] *សូមមើល ខាងលើ* ជើងទំព័រ ១។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចលើពាក្យសុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១៧, ឯកសារ D350/1/1/3 ("ចម្លើយតប") ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៧។

5. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ស.ច.ស.អ បានដាក់ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤)នៃវិធានផ្ទៃក្នុង ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ")[12] ។ សហមេធាវីបានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៧ ជំទាស់ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ[13] និងសារណាស្តីពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧[14]។

## III ភាពអាចទទួលយកបាន

6. សហមេធាវីលើកឡើងថាបណ្តឹងឧទ្ធរណ៍នេះ អាចឱ្យទទួលយកបានអនុលោមតាមវិធាន៧៤(៣)(ឆ)[15]និងគូសបញ្ជាក់ទៀតថាសិទ្ធិប្តឹងឧទ្ធរណ៍ត្រូវបានគាំទ្រក្នុងវិធាន ៧៦(២)[16]។ ស.ព.អ ពុំជំទាស់អំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះឡើយ[17]។ អង្គបុរេជំនុំជម្រះយល់ឃើញថាសេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ និងបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ក្នុងរយៈពេលដែលមានចែងក្នុងវិធាន៧៥(១)និង(៣)នៃវិធានផ្ទៃក្នុង និងថាបណ្តឹងឧទ្ធរណ៍នេះអាចឱ្យទទួលយកបានអនុលោមតាមវិធាន៧៤(៣)(ឆ)។

## IV. អង្គសេចក្តី

7. សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះ i) ច្រានចោលដីកាសម្រេចដែលរងការជំទាស់ ii) ពិចារណាអំពីពាក្យសុំលើអង្គសេចក្តី និង iii) សម្រេចថាដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ មិនអាច

---

[12] ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន៦៦(៤)នៃវិធានផ្ទៃក្នុង, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៧ ឯកសារ D351។

[13] ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍លើដីការបស់សហចៅក្រមស៊ើបអង្កេតបញ្ជូនសំណុំរឿងទៅពិនិត្យអនុលោមតាមវិធាន៦៦(៤) នៃវិធានផ្ទៃក្នុង, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៧, ឯកសារ D351/2, ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៧។

[14] បណ្តឹងឧទ្ធរណ៍ចំពោះដីកាបញ្ជូនសំណុំរឿងទៅពិនិត្យអនុលោមតាមវិធាន៦៦(៤)នៃវិធានផ្ទៃក្នុង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៧, ឯកសារ D351/2/2, ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេសនៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៧ និងជាភាសាខ្មែរនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧។

[15] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២២, ២៤។

[16] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៣។

[17] ចម្លើយតប, កថាខណ្ឌ ៩។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * C.E.C. * C.E.T.C.

ត្រូវបានចេញដោយស្របច្បាប់ឡើយ រហូតទាល់តែមានការសម្រេចលើបណ្តឹងឧទ្ធរណ៍[18]។ ពួកគាត់បានលើកឡើងនូវទឡ្ហីករណ៍សំខាន់ៗចំនួន ២ ដែលមានជាអាទិ៍ ក) ស.ច.ស.អ បានប្រព្រឹត្តកំហុសអង្គច្បាប់ និង/ឬ អង្គហេតុ ក្នុងការសម្រេចថាពាក្យសុំ "គ្មានមូលដ្ឋានជាក់លាក់" ("ទឡ្ហីករណ៍ទីមួយ")[19] និង ខ) ស.ច.ស.អ បានប្រព្រឹត្តកំហុសក្នុងការសម្រេចថាគ្មានភាពចាំបាច់ដើម្បីរង់ចាំរហូតដល់ពេលមានការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដើម្បីបញ្ជូនសំណុំរឿងទៅសហព្រះរាជអាជ្ញា ("ទឡ្ហីករណ៍ទីពីរ")[20]។

8. ទឡ្ហីករណ៍ទីមួយផ្អែកលើមូលដ្ឋានចំនួន ៣ ដែលរួមមាន i) ការសម្រេចរបស់ ស.ច.ស.អ ដែលថាវិការៈដែលត្រូវបានចោទប្រកាន់ត្រូវបានដាក់ពិន័យ រួចហើយដោយអង្គបុរេជំនុំជម្រះ គឺផ្អែកលើកំហុសអង្គហេតុ និង/ឬអង្គច្បាប់ ដោយហេតុថា ការរំលោភដែលបានលើកឡើងក្នុងពាក្យសុំនេះពុំដែលត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ មុនពេលដាក់ឯកសារនេះឡើយ ពុំដែលត្រូវបានពិចារណាដោយអង្គជំនុំជម្រះ ហើយ ក្នុងករណីណាក៏ដោយ *ទស្សនៈចៅក្រម* ក្នុងមតិភាគតិច ពុំមែនជាសេចក្តីសម្រេចដែលចងកាតព្វកិច្ចឡើយ[21] ii) ការសម្រេចរបស់ ស.ច.ស.អ ដែលថាការរំលោភដែលត្រូវបានចោទប្រកាន់ទៅលើសិទ្ធិរបស់ [redacted] ពុំមែនជាវិការៈសម្រាប់គោលបំណងនៃពាក្យសុំអនុលោមតាមវិធាន៧៦ គឺផ្អែកលើកំហុសអង្គហេតុ និង/ឬ អង្គច្បាប់ ដោយហេតុថា "ការរំលោភវិធានផ្ទៃក្នុង និង/ឬ [សិទ្ធិក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR)] ជាវិការៈសម្រាប់គោលបំណងនៃពាក្យសុំអនុលោមតាមវិធាន ៧៦"[22] និង iii) ការសម្រេចរបស់ ស.ច.ស.អ ដែលថាការរំលោភដែលត្រូវបានចោទប្រកាន់ពុំអាចធ្វើយុត្តិកម្មចំពោះពាក្យសុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល គឺផ្អែកលើកំហុសអង្គហេតុ និង/ឬ អង្គច្បាប់

[18] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២។

[19] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៣៩-៥៥។

[20] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៦-៥៩។

[21] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០-៥១ ដោយយោងទៅរកដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៧-៨។

[22] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥២-៥៤។

ដោយហេតុថាពាក្យសុំ "លើកករណីមួយដែលអាចជជែកតវ៉ាបាន សម្រាប់អត្ថិភាពនៃការរំលោភដែលបានប៉ះពាល់ភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរទាំងមូល"[23]។

9. ក្នុងទឡ្ហីករណ៍ទីពីរ សហមេធាវីអះអាងថាក្នុងការសម្រេចថាពុំមានភាពចាំបាច់ក្នុងការរង់ចាំរហូតដល់ពេលមានការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដើម្បីបញ្ជូនសំណុំរឿងនេះទៅសហព្រះរាជអាជ្ញា ស.ច.ស.អ "បានខកខានពុំបានពិចារណាថាបណ្តឹងឧទ្ធរណ៍នេះលើកអំពីបញ្ហាដែលមានសារៈសំខាន់ជាសារវ័ន្ត - បញ្ហានៃការបកស្រាយដ៏ត្រឹមត្រូវអំពីលក្ខណៈចងកាតព្វកិច្ចនៃយោបល់ដាច់ដោយឡែករបស់ចៅក្រមនានានៃ[អង្គបុរេជំនុំជម្រះ]" ដែលអាចតម្រូវឱ្យភាគីកែប្រែសារណារបស់ពួកគាត់[24]។

10. ជាការឆ្លើយតប ស.ព.អ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះ សំណើសុំផ្អាកដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ និងពាក្យសុំនេះទាំងស្រុង[25]។ ស.ព.អ លើកឡើងថា ស.ច.ស.អ "បានសម្រេចយ៉ាងត្រឹមត្រូវក្នុងការមិនស្នើសុំឱ្យ [អង្គបុរេជំនុំជម្រះ] ពិនិត្យនិងចាត់ការ [...] ពាក្យសុំ ដោយសំអាងថាពាក្យសុំ "គ្មានមូលដ្ឋានជាក់លាក់"[26]។ ស.ព.អ អះអាងថាពាក្យសុំ "ពុំបង្ហាញអំពីវិការៈនីតិវិធីដែលអាចកំណត់អត្តសញ្ញាណបានឡើយ"[27] ដោយហេតុថាវាត្រូវបានចាត់ទុកជា "សំណើសុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល" ដែលអង្គបុរេជំនុំជម្រះ បានឆ្លើយតបរួចរាល់ទៅហើយ[28]។ ស.ព.អ លើកទឡ្ហីករណ៍ថាជាមូលដ្ឋាន ពាក្យសុំជាបណ្តឹងជំទាស់ដីកាសម្រេចរបស់ ស.ច.ស.អ ដែលបានបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយ ដែលបើកផ្លូវប្តឹងឧទ្ធរណ៍ ពុំអាចកែប្រែចំពោះនីតិវិធីនៃការធ្វើមោឃភាពឡើយ[29]។ ស.ព.អ បន្ថែមថា

---

[23] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៥ ដោយយោងទៅរកដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨-៩, ១៤។

[24] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៥៦-៥៨។

[25] ចម្លើយតប, កថាខណ្ឌ ២៤។

[26] ចម្លើយតប, កថាខណ្ឌ ១០។

[27] ចម្លើយតប, កថាខណ្ឌ ១២។

[28] *ដូចឯកសារយោងខាងលើ* ដោយយោងទៅរកយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០២ ដែលចែងថា "នីតិវិធីនៃការធ្វើមោឃភាពពុំត្រូវបានបង្កើតឡើងដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅឡើយ"។

[29] ចម្លើយតប, កថាខណ្ឌ ១៣-១៤។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE C.C.C * C.E.T.C

អ្នកដាក់ពាក្យសុំ "អស់ពេលវេលាជាយូរមកហើយក្នុងការប្ដឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចទាំងនោះ"[30] ហើយថាក្នុងបណ្ដឹងឧទ្ធរណ៍ដទៃ សហមេធាវីបានលើកទឡ្ហីករណ៍រួចហើយថា "ស.ច.ស.អ បានប្រព្រឹត្តកំហុសក្នុងការកំណត់លក្ខខណ្ឌនៃភាពជាក់លាក់ និងភាពពាក់ព័ន្ធក្នុងកម្រិតខ្ពស់ដែលមានលក្ខណៈជាការហាមឃាត់ ដោយយោងទៅលើការរិតត្បិតដែលត្រូវបានដាក់ទៅលើលទ្ធភាពរបស់ [redacted] ក្នុងការបំពេញកិច្ចស៊ើបសួរ"[31] ដែលទឡ្ហីករណ៍នេះត្រូវបានពិចារណាដោយចៅក្រមនៃអង្គបុរេជំនុំជម្រះ[32]។

11. ស.ព.អ បានលើកឡើងទៀតថាវិធានផ្ទៃក្នុងពុំតម្រូវឱ្យ ស.ច.ស "ផ្អាកការចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ដោយសារតែភាគីមួយបានស្នើសុំការធ្វើមោឃភាពកិច្ចស៊ើបសួរឡើយ"[33] និងថា "វិធាន៧៦(២) គ្រាន់តែតម្រូវថា ស.ច.ស ត្រូវសម្រេចលើសំណើសុំធ្វើមោឃភាពមុនពេលចេញដីកាដំណោះស្រាយ [ហើយ] វិធាន ៦៦(២)-(៤) គ្រាន់តែតម្រូវថាបណ្ដឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចដែលបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ពុំមែនសំណើសុំធ្វើមោឃភាព ត្រូវសម្រេច មុនពេលចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦(៤)"[34]។

### ខ. ពិភាក្សា

*លក្ខខណ្ឌដែលត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេត៖*

12. អនុលោមតាមវិធាន៤៨នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រនៃអង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតត្រូវតែពិចារណាពាក្យសុំជូនដំណឹងទៅអង្គបុរេជំនុំជម្រះ ឱ្យពិនិត្យនិងចាត់ការលើការធ្វើមោឃភាពលើទិដ្ឋភាពចំនួន២៖ ទីមួយ ពាក់ព័ន្ធទៅនឹងថាតើពាក្យសុំនោះកំណត់អត្តសញ្ញាណនៃ

---

[30] ចម្លើយតប, កថាខណ្ឌ ១៤។

[31] ចម្លើយតប, កថាខណ្ឌ ១៥ ដោយយោងទៅរកបណ្ដឹងឧទ្ធរណ៍ ជើងទំព័រ ៧០។

[32] *ដូចឯកសារយោងខាងលើ*។

[33] ចម្លើយតប, កថាខណ្ឌ ២២។

[34] *ដូចឯកសារយោងខាងលើ*។

វិការៈនីតិវិធីដែរឬទេ និងទីពីរ ពាក់ព័ន្ធទៅនឹងថាតើពាក្យសុំនេះបង្ហាញអត្ថសញ្ញាណនៃព្យសនកម្ម ដែលបានបង្កឡើងដោយវិការៈបែបនេះ ចំពោះអ្នកដាក់ពាក្យសុំដែរឬទេ[35]។

13. នៅពេលប្រឈមជាមួយបណ្តឹងឧទ្ធរណ៍ ដែលធ្វើអនុលោមតាមវិធាន៧៤(៣)(ឆ)នៃវិធានផ្ទៃក្នុង ជំទាស់ដីកាសម្រេចដែលចេញដោយអនុលោមតាមវិធាន៧៦(២) អង្គបុរេជំនុំជម្រះបានមានឱកាសដើម្បីបង្ហាញលក្ខខណ្ឌវិនិច្ឆ័យនៃ "ករណីដែលអាចតវ៉ាបាន" នៅពេលកំណត់អំពីលក្ខខណ្ឌដែលសហចៅក្រមស៊ើបអង្កេតត្រូវបំពេញ[36] និងបានពិចារណាឃើញថា "ការសម្រេចរបស់ ក.ស.ច.ស អំពីថាតើករណីមួយ "អាចតវ៉ាបាន" ដែរឬទេ គឺជាការបញ្ជាក់ថាសំណើនេះពុំមែន "គ្មានមូលដ្ឋានជាក់លាក់" ឡើយ ក្នុងអត្ថន័យនៃវិធាន៧៦(៤)នៃវិធានផ្ទៃក្នុង។ សំណើមួយ "គ្មាន

---

[35] សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៣") (អ.ប.ជ ២៨) សាលដីកាលើ ១) បណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើចំនួន៩ សុំប្តឹងទៅអង្គបុរេជំនុំជម្រះឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរ និង ២) លើសំណើសុំចំនួន ២ ដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេត, ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦, ឯកសារ D165/2/26 ("សាលដីកាលើពាក្យសុំចំនួន៩") កថាខណ្ឌ ៣៨ *ដោយយោងទៅលើ*សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០២") (អ.ប.ជ ០៦), សាលដីកាលើបណ្តឹងឧទ្ធរណ៍ នួន ជា ជំទាស់ដីកាបដិសេធសំណើសុំធ្វើមោឃភាព, ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨, ឯកសារ D55/I/8 ("សាលដីកា នួន ជា") កថាខណ្ឌ ២៣។ សំណុំរឿង ០០២ (អ.ប.ជ ៤១), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យ អង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1), ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០, ឯកសារ D263/2/6 ("សាលដីកា អៀង ធីរិទ្ធ") កថាខណ្ឌ ១៨។ សំណុំរឿង ០០៣ (អ.ប.ជ ២០), សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត Harmon ដែលសម្រេចលើពាក្យសុំរបស់ [redacted] ស្នើឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យនិងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ, ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៥, ឯកសារ D134/1/10 ("សាលដីកាលើពាក្យសុំមោឃភាពចំនួន២") កថាខណ្ឌ ១៩។

[36] សាលដីកាលើពាក្យសុំចំនួន៩, កថាខណ្ឌ ៣៩ *ដោយយោងទៅលើ* សំណុំរឿង ០០២ (អ.ប.ជ ៧២), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់ ក.ស.ច.ស សម្រេចបដិសេធសំណើរបស់គាត់សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ឬដោយមានជំនួយពីលោក David Boyle និងលោក Stephen Heder និងលើសំណើរបស់លោក អៀង សារី សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពភស្តុតាងទាំងឡាយដែលប្រមូលពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្តឹងឧទ្ធរណ៍បន្ទាន់ប្រឆាំងនឹងការបដិសេធរបស់ ក.ស.ច.ស លើការផ្អាកកិច្ចដំណើរការនីតិវិធី, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០, ឯកសារ D402/1/4 ("សាលដីកា អៀង សារី") កថាខណ្ឌ ១៩ ដោយដកស្រង់សាលដីកា អៀង ធីរិទ្ធ, កថាខណ្ឌ ១៧។

មូលដ្ឋានជាក់លាក់" នៅតែពេលដែលវាមានភាពជាក់ស្តែង ឬជាក់ច្បាស់ដែលថាវាគ្មានមូលដ្ឋានគតិយុត្តិ ឬមូលដ្ឋានអង្គហេតុ និងគ្មានលទ្ធភាពនៃជោគជ័យ។ ជាងនេះទៀត អង្គជំនុំជម្រះសូមរម្លឹកថាសហចៅក្រមស៊ើបអង្កេត ត្រូវតែវាយតម្លៃថាតើសំណើនេះ *តាមការពិនិត្យបឋម* ឬផ្នែកខាងក្រៅរបស់វា បង្ហាញ "ទឡ្ហីករណ៍ដែលមានសំអាងហេតុ" ដែលអះអាងអំពីវិការៈនីតិវិធី និងព្យសនកម្មដែរឬទេ ប៉ុន្តែមិនត្រូវសម្រេចតែទៅលើមូលដ្ឋានដែលបានលើកក្នុងសំណើសុំធ្វើមោឃភាពឡើយ"[37]។ ហេតុដូច្នេះ "ការសម្រេចដែលថា "ករណីមួយដែលអាចតវ៉ាបាន" ត្រូវបានធ្វើសន្មតជាមុនត្រឹមតែថាសហចៅក្រមស៊ើបអង្កេតធ្វើឱ្យខ្លួនឯងជឿជាក់ថា៖ (១) សំណើ *តាមការពិនិត្យបឋម* លើកឡើងអំពីទឡ្ហីករណ៍ដែលមានសំអាងហេតុ និង (២) សំណើនេះពុំមែនគ្មានមូលដ្ឋានជាក់លាក់ឡើយ"[38]។

*បទដ្ឋានសម្រាប់ការពិនិត្យដីកាសម្រេចរបស់ ក.ស.ច.ស៖*

14. អនុលោមតាមយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដីកាសម្រេចរបស់ ក.ស.ច.ស អាចត្រូវបានច្រានចោលប្រសិនបើដីកានោះ ក) ផ្អែកលើកំហុសអង្គហេតុដែលធ្វើមោឃភាពដីកាសម្រេចនោះ ខ) ផ្អែកលើកំហុសអង្គហេតុដែលបណ្តាលឱ្យមានការសម្រេចដោយមិនយុត្តិធម៌ ឬ គ) មិនមានយុត្តិធម៌ ឬមិនមានភាពសមហេតុផលរហូតដល់ជាការបំពានឆន្ទានុសិទ្ធិរបស់ចៅក្រម[39]។

*ករណីនៅចំពោះមុខ*

15. សហមេធាវីលើកឡើងថាការសម្រេចរបស់ ស.ច.ស.អ ដែលថាពាក្យសុំ "គ្មានមូលដ្ឋានជាក់លាក់" "សំអាងលើការវាយតម្លៃដែលមិនត្រឹមត្រូវរបស់ ស.ច.ស.អ ដែលថាវិការៈ ឬការរំលោភដែលបានលើកក្នុងពាក្យសុំធ្វើមោឃភាព ត្រូវបាន "ដាក់ទណ្ឌកម្ម" រួចហើយដោយ អ.ប.ជ"[40]។

---

[37] សាលដីកាលើពាក្យសុំចំនួន៩, កថាខណ្ឌ ៤០ ដោយយោងទៅរក សាលដីកា អៀង សារី កថាខណ្ឌ ១៨។

[38] សាលដីកាលើពាក្យសុំចំនួន៩, កថាខណ្ឌ ៤១។

[39] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០៤ (អ.ប.ជ ២៤) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦, ឯកសារ D260/1/1/3 កថាខណ្ឌ ១៥។

[40] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤០។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បន្ទាប់ពីបានពិនិត្យដីកាសម្រេចដែលរងការជំទាស់ អង្គបុរេជំនុំជម្រះសង្កេតឃើញថា ស.ច.ស.អ ពុំបានសំអាងទាំងស្រុងទៅលើការសម្រេចដែលថា "សហមេធាវីស្នើសុំឱ្យ អ.ប.ជ ពិចារណាឡើងវិញអំពីទស្សនៈរបស់ខ្លួន" ឡើយ។ ប៉ុន្តែ ការសម្រេចនេះគឺជាផ្នែកដាច់ដោយឡែកមួយនៃសំអាងហេតុទាំងមូលដែលត្រូវបានផ្តល់ក្នុងដីកាសម្រេចដែលរងការជំទាស់។ ប្រការសំខាន់ជាងនេះ ដីកាសម្រេចដែលរងការជំទាស់ក៏បានសម្រេចថា "មេធាវីការពារក្តីមិនបានកំណត់អត្តសញ្ញាណវិការៈនីតិវិធីណាមួយទាក់ទងកិច្ចស៊ើបសួរណាមួយ ឬទាក់ទងផ្នែកណា មួយកិច្ចដំណើរការនីតិវិធីក្នុងអត្ថន័យនៃវិធាន៧៦ឡើយ"[41]និងថា "ការយោងដែលបានធ្វើក្នុងពាក្យសុំនេះទៅរកដីកាសម្រេចមុនរបស់ អ.ប.ជ [...] គឺពុំត្រឹមត្រូវ [និង] លុបចោលប្រយោគដ៏សំខាន់មួយ [ដែលថា] នីតិវិធីនៃការធ្វើមោឃភាព [...] ពុំត្រូវបានបង្កើតឡើងដើម្បីធ្វើមោឃភាពកិច្ចស៊ើបសួរជាទូទៅឡើយ"[42] និងបានសន្និដ្ឋានថា៖ "មូលដ្ឋានគតិយុត្តិសម្រាប់ការធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូលកំពុងខ្វះខាតជាក់ស្តែងរួចទៅហើយ"[43] និងថា "ប្រសិនបើ អ.ប.ជ សម្រេចធ្វើមោឃភាពកិច្ចស៊ើបសួរនេះទាំងស្រុង [...] ខ្ញុំមិនឃើញលទ្ធភាពជាក់ស្តែងនៃការកើតមានដូច្នោះឡើយ"[44]។

16. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា៖ i) ការសម្រេចរបស់ ស.ច.ស.អ ដែលថាពាក្យសុំ "គ្មានមូលដ្ឋានជាក់លាក់" ពុំ "សំអាង" លើការបញ្ជាក់របស់ ស.ច.ស.អ ដែលថាវិការៈ ឬការរំលោភដែលបានលើកក្នុងពាក្យសុំត្រូវបាន "ដាក់ពិន័យ" រួចហើយដោយ អ.ប.ជ និងថា ii) ការសម្រេចរបស់ ស.ច.ស.អ គឺផ្អែកលើការសម្រេចដែលថាពាក្យសុំ *តាមការពិនិត្យបឋម* ពុំបានលើកឡើងអំពីទឡ្ហីករណ៍ដែលមានសំអាងហេតុតាមរយៈការអះអាងអំពីវិការៈនីតិវិធី និងព្យសនកម្មឬពុំបានធ្វើសំណើដែលមានមូលដ្ឋានគតិយុត្តិឬមូលដ្ឋានអង្គហេតុ ដែលអនុលោមតាមវិធាន៤៨ នៃវិធានផ្ទៃក្នុងនិងយុត្តិសាស្ត្រនៃអង្គបុរេជំនុំជម្រះ ទាក់ទងលក្ខខណ្ឌដែលត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។

---

[41] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៨ (សេចក្តីបញ្ជាក់បន្ថែម)។

[42] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ៩ *ដោយយោងទៅរក* ដីកាសម្រេច អ.ប.ជ ក្នុងសំណុំរឿង ០០២ D263/2/6 កថាខណ្ឌ ២៤ (សេចក្តីបញ្ជាក់បន្ថែម)។

[43] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៣ (សេចក្តីបញ្ជាក់បន្ថែម)។

[44] ដីកាសម្រេចដែលរងការជំទាស់, កថាខណ្ឌ ១៤ (សេចក្តីបញ្ជាក់បន្ថែម)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * C.E.T.C *

01530453



17. អង្គបុរេជំនុំជម្រះយល់ស្របជាមួយការសម្រេច និងសេចក្តីសន្និដ្ឋានរបស់ ស.ច.ស.អ ក្នុងដីកាសម្រេចដែលរងការជំទាស់ ត្រង់ថាតាមរយៈការជំទាស់ទៅនឹងទស្សនៈគតិយុត្តិរបស់ ស.ច.ស.អ ដែលខុសពីការជំទាស់ទៅនឹងផ្នែកនានានៃកិច្ចស៊ើបសួរ សហមេធាវីបានខកខានពុំបានលើកឡើងអំពីទឡ្ហីករណ៍ដែលមានមូលដ្ឋានគតិយុត្តិ ឬមូលដ្ឋានអង្គហេតុសម្រាប់វិការៈនីតិវិធី។

18. លើសពីនេះ អង្គបុរេជំនុំជម្រះសូមរម្លឹកថាខ្លួនបានបដិសេធជាឯកច្ឆន្ទ[45] បណ្តឹងឧទ្ធរណ៍មួយទៀតដែលត្រូវបានដាក់ជំទាស់ដីកាសម្រេចរបស់ ស.ច.ស.អ ដែលបានបដិសេធទឡ្ហីករណ៍ស្រដៀងនេះរបស់សហមេធាវី ដែលថា "ក.ស.ច.ស ពុំអាចរិតត្បិតធ្ងន់ធ្ងរលើលទ្ធភាពរបស់មេធាវីការពារក្តីក្នុងការប្រមូលព័ត៌មាន និងបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី ដោយសំអាងថាមិនមានព័ត៌មាននោះឡើយ។ ស្ថានភាពនេះ *ធ្វើឱ្យ* មេធាវីការពារក្តីពុំអាចចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចស៊ើបសួរ និងប៉ះពាល់សិទ្ធិរបស់គាត់ក្នុងការទទួលបានដំណើរការប្រកបដោយយុត្តិធម៌"[46]។ ជាលទ្ធផលនៃការបដិសេធជាឯកច្ឆន្ទនូវបណ្តឹងឧទ្ធរណ៍នោះ ដីកាសម្រេចរបស់ ស.ច.ស.អ ដែលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរនៅតែមានសុពលភាព។ អង្គបុរេជំនុំជម្រះពុំជឿជាក់លើទឡ្ហីករណ៍របស់សហមេធាវី ដែលថាបញ្ហាដែលត្រូវបានចោទប្រកាន់នៃ "អន្តរកម្ម" រវាងការបកស្រាយរបស់ ស.ច.ស.អ អំពីបទដ្ឋាននៃសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងការហាមឃាត់មិនឱ្យមេធាវីការពារក្តីបំពេញកិច្ចស៊ើបសួរដោយខ្លួនឯង[47] ឬ "ភាពមិនអាចផ្សះផ្សាបាន" នៃជំហាទាំងពីរនេះ[48] ត្រូវបានលើកឡើងថ្មីៗក្នុងពាក្យសុំនេះ[49]។ ក្នុងពាក្យសុំនាពេលបច្ចុប្បន្ន សហមេធាវីលើកឡើងជាមូលដ្ឋាននូវដូចទឡ្ហីករណ៍សន្និដ្ឋានរបស់ពួកគាត់ក្នុងបណ្តឹងឧទ្ធរណ៍មុន ប៉ុន្តែសំណូមពរដែលត្រូវបានស្នើសុំនាពេលនេះត្រូវបានហៅថាជាសំណើសុំធ្វើមោឃ

---

[45] សំណុំរឿង ០០៤ (អ.ប.ជ ៣៣) សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចលើសំណើទីប្រាំមួយរបស់ [redacted] សុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៧, ឯកសារ D276/1/1/3 ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់សំណើទី៦") ផ្នែកសម្រេចសេចក្តី។ សូមមើលផងដែរ សាលដីកាលើបណ្តឹងឧទ្ធរណ៍ជំទាស់សំណើទី៦, កថាខណ្ឌ ២៤៖ "ដែលពិចារណាឃើញថាមិនមានភាពចាំបាច់ដើម្បីបំពេញកិច្ចស៊ើបសួរដែលត្រូវបានស្នើសុំ"។

[46] បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយរបស់ [redacted], ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦, ឯកសារ D276/1/1/1, កថាខណ្ឌ ៣២ "សន្និដ្ឋាន និងសំណើសុំដំណោះស្រាយ" (សេចក្តីបញ្ជាក់បន្ថែម)។

[47] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២, ៥៣។

[48] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២។

[49] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៤២, ៥៤។



អង្គបុរេជំនុំជម្រះ * C.E.C.T. * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ភាពកិច្ចស៊ើបសួរទាំងមូល។ ពាក្យសុំធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល ពុំមែនជាមធ្យោបាយដ៏ត្រឹមត្រូវសម្រាប់ការជំទាស់កំហុសអង្គហេតុដែលត្រូវបានចោទប្រកាន់របស់ ស.ច.ស.អ ដែលបានធ្វើក្នុងដីកាសម្រេចនានាដែលបដិសេធសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរឡើយ។

19. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនជឿជាក់លើទឡ្ហីករណ៍ទីមួយរបស់សហមេធាវីឡើយ។

20. អង្គបុរេជំនុំជម្រះឯកភាពជាមួយ ស.ច.ស.អ ដែលថាពុំមានភាពចាំបាច់ដែលត្រូវរង់ចាំរហូតទាល់តែមានការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះ ដើម្បីបញ្ជូនសំណុំរឿងនេះទៅសហព្រះរាជអាជ្ញា[50]។ បញ្ហាដែលបានលើកក្នុងបណ្តឹងឧទ្ធរណ៍នេះ ទាក់ទងការបកស្រាយអំពីលក្ខណៈចងកាតព្វកិច្ចនៃទស្សនៈរបស់ចៅក្រមនានានៃអង្គបុរេជំនុំជម្រះ ពុំមែនជាការសម្រេចលើដីកាសម្រេចដែលរងការជំទាស់[51] និងដីកាសន្និដ្ឋានស្ថាពររបស់ភាគីឡើយ។ លើសពីនេះ ដូចដែល ស.ព.អ គូសបញ្ជាក់ផងដែរ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាវិធាន៦៦(១)-(៤) នៃវិធានផ្ទៃក្នុងតម្រូវថាមានតែបណ្តឹងឧទ្ធរណ៍ជំទាស់ដីកាសម្រេចដែលបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរប៉ុណ្ណោះ ដែលត្រូវសម្រេចមុនពេលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុលោមតាមវិធាន៦៦(៤)។ ប៉ុន្តែសំណើសុំធ្វើមោឃភាពអាចត្រូវបានសម្រេច "មុនពេលមានដីកាដំណោះស្រាយ"[52]។ ហេតុដូច្នេះ ភាពយុត្តិធម៌នៃនីតិវិធី ពុំត្រូវបានស្ថិតក្រោមហានិភ័យ នៅពេលដែល ស.ច.ស.អ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ អង្គបុរេជំនុំជម្រះក៏ពុំយល់ឃើញថាមានមូលដ្ឋានក្នុងទឡ្ហីករណ៍ទីពីររបស់សហមេធាវីផងដែរ។

21. សរុបសេចក្តី អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍នេះទាំងស្រុង។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

- **យល់ឃើញថាបណ្តឹងឧទ្ធរណ៍មិនអាចទទួលយកបាន**

---

[50] សូមមើល ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ ១៤។

[51] *សូមមើល ខាងលើ* កថាខណ្ឌ ១៥។

[52] វិធាន៧៦(២)នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ៤៣)

ឯកសារលេខD350/1/1/4

- **បដិសេធបណ្តឹងឧទ្ធរណ៍។**

អនុលោមតាមវិធាន៧៧(១៣)នៃវិធានផ្ទៃក្នុង ដីកាសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៧**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន Olivier BEAUVALLET ន័យ ថុល KangJin BAIK ហួត វុទ្ធី**